# drumMUSTER

ដ្រាំម៉ាស្ទើរ

# ជួយធ្វើឲ្យមានការងាយស្រួល

ការយកប្រើប្រាស់ម្តងទៀតនូវធុងដាក់ថ្នាំគីមីសំរាប់ស្រែចំការ **drumMUSTER** ដែលលោកអ្នកមានសិទ្ធិប្រើប្រាស់គឺជាការងាយស្រួលទេ – លោកអ្នកគ្រាន់តែធ្វើតាមជំហានងាយស្រួលដូចតទៅនេះប៉ុណ្ណោះ៖



✓ បាញ់ទឹកលាងជំរះ ឬលាងជំរះធុងថ្នាំគីមីចំនួន៣ដង ឲ្យបានភ្លាមៗ បន្ទាប់ពីប្រើវា



✓ ចាក់ទឹកលាងជំរះដែលបានប្រើរួច ចូលទៅក្នុងធុងសំរាប់ដាក់ទឹកបាញ់ថ្នាំគីមីវិញ



✓ ឲ្យបានច្បាស់ប្រាកដថា អ្នកត្រូវយកកាកសំណល់ថ្នាំគីមីទាំងអស់ចេញពីធុង

✓ បើកគំរបធុងចេញ ដើម្បីឲ្យធុងរបស់អ្នកស្ងួតសព្វទីកន្លែង។ យកគំរបធុងដាច់ដោយឡែកពីធុងទៅកាន់កន្លែងប្រមូលយកធុង។



✓ អ្នកត្រូវចាក់ទំលុះធុងដែកចាប់ពីគំរបធុងទៅបាតក្រោមធុង។



✓ ដឹកធុងទទេដែលអ្នកមានសិទ្ធិប្រើប្រាស់ ហើយបានលាងជំរះស្អាតទៅកាន់មណ្ឌលប្រមូល *drumMUSTER* ក្នុងតំបន់របស់អ្នក

ដើម្បីទទួលយកព័ត៌មានពិស្តារស្តីអំពីការប្រមូលធុង **drumMUSTER** ក្នុងតំបន់របស់អ្នក សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់អ្នក ឬបើកមើលវ៉ិបសាយរបស់ **drumMUSTER** នៅត្រង់កន្លែង៖

**www.drummuster.com.au**

**drumMUSTER**

# ជំនួយខ្លះៗអំពីការលាងជំរះធុង

ជំនួយដូចតទៅនេះនឹងជួយអ្នកឲ្យបានច្បាស់ប្រាកដថា ការលំបាក លាងជំរះរបស់អ្នក នូវធុងថ្នាំគីមីសំរាប់ស្រែចំការដែលអ្នកមាន សិទ្ធិប្រើប្រាស់ នឹងត្រូវបានគេទទួលយកទៅប្រើប្រាស់ម្តងទៀត នៅមណ្ឌលប្រមូល drumMUSTER ក្នុងតំបន់របស់អ្នក។




## ថ្នាំគីមីដែលត្រូវបានបញ្ឈប់ឲ្យប្រើបណ្តោះអាសន្ន

(ដូចជាថ្នាំគីមី Atrazine, Simazine ជាដើម)

✓ លាងជំរះធុងថ្នាំរបស់អ្នកឲ្យបានភ្លាមៗបន្ទាប់ពីប្រើវា ដើម្បីកុំឲ្យកាកសំណល់ថ្នាំគីមីវាស្ងួត

✓ ប្រើថ្នាំអាកុលដើម្បីលាងជំរះកាកសំណល់ថ្នាំគីមី។ ប្រសិនបើការនេះធ្វើមិនបានល្អទេ ចាក់ទឹកបំពេញធុងថ្នាំដោយត្រាំវាទុកឲ្យបានយ៉ាងតិច២៤ម៉ោង មុននឹងលាងជំរះវា



## ថ្នាំគីមីដែលមានជាតិប្រេង

(ULVs - ចំណុះតិចបំផុត, LVs - ចំណុះតិច)



✓ ធ្វើទៅតាមការណែនាំជាក់លាក់ដែលមានដាក់នៅពីលើផ្លាកផលិតផល ឬទាក់ទងជាមួយអ្នកផលិតដើម្បីទទួលយកជំនួយបន្ថែមទៀត

## កាកសំណល់ថ្នាំគីមីឯទៀត



✓ លាងជំរះធុងថ្នាំគីមីឲ្យបានភ្លាមបន្ទាប់ពីប្រើវា ដោយហេតុថាកាកសំណល់ថ្នាំគីមីទាំងអស់ពិបាកនឹងលាងជំរះណាស់ កាលណាទុកឲ្យវាស្ងួត

✓ ធុងថ្នាំគីមីខ្លះអាចតម្រូវឲ្យមានការលាងជំរះបន្ថែមទៀត (លាងជំរះលើសពី៣ដង)



✓ អ្នកប្រហែលជាត្រូវប្រើច្រាសដុះ ឬប្រើទុយយោបាញ់ទឹកលាងជំរះនូវកាកសំណល់ថ្នាំគីមីដែលជាប់ស្អិត ឬស្ងួត

✓ ធុងថ្នាំគីមីដែលអ្នកមានសិទ្ធិប្រើប្រាស់ដែលជាប់ធូលីដី ច្រេះស៊ី ហើយប្រឡាក់ថ្នាំ មិនបានចាត់ទុកថាមានគ្រោះថ្នាក់ឡើយ ហើយអាចទទួលយកបាននៅតាមមណ្ឌលប្រមូល *drumMUSTER*

ដើម្បីទទួលយកព័ត៌មានបន្ថែមទៀតស្តីអំពីការលាងសំអាតធុង សូមទាក់ទងជាមួយអ្នកលក់ថ្នាំគីមីបន្តសំរាប់ស្រែចំការ Agsafe ដែលបានទទួលស្គាល់ជាផ្លូវការក្នុងតំបន់របស់អ្នក ឬបើកមើលនៅត្រង់វ៉ិបសាយ

www.drummuster.com.au

**drum**MUSTER